**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលរាជធានីភ្នំពេញ**

គណៈកម្មាធិការលទ្ធកម្មរាជធានីភ្នំពេញ

លេខ ១៣៩ គល

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង

## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ

## ការងារជួសជុលចាក់បេតុងឆ្អឹងដែក កំរាស់ ១៥ស.ម ផ្លូវលំភូមិព្រៃជីសាក់ ផ្ទៃក្រឡា៣,០០០ម៉ែត្រការ៉េ និងដាក់លូមូលទំហំ ១ម៉ែត្រ ក្នុងសាច់ផ្លូវ ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ, ផ្លូវលំភូមិស្រុកចេក ផ្ទៃក្រឡា ៨,៥២០ម៉ែត្រការ៉េ ក្នុងសង្កាត់ជើងឯក ខណ្ឌដង្កោ និងផ្លូវលំភូមិត្រពាំងរំចេកផ្ទៃក្រឡា៨,៨០០ ម៉ែត្រការ៉េ ក្នុងខណ្ឌពោធិ៍សែនជ័យ និង ខណ្ឌដង្កោ រាជធានីភ្នំពេញ

## ជូនរដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៧

រដ្ឋបាលរាជធានីភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក( គិតទាំងសហគ្រាសឯកត្តបុគ្គល) និងក្រុមហ៊ុនបរទេសទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា រដ្ឋបាលរាជធានីភ្នំពេញ នឹង ដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារជួសជុលចាក់បេតុងឆ្អឹងដែក កំរាស់ ១៥ស.ម ផ្លូវលំភូមិព្រៃជីសាក់ បណ្តោយ៥០០ម៉ែត្រ ទទឹង៦ម៉ែត្រ ផ្ទៃក្រឡា៣,០០០ម៉ែត្រការ៉េ និង ដាក់លូមូលទំហំ ១ម៉ែត្រ ក្នុងសាច់ផ្លូវ ចាប់ពីផ្លូវសហព័ន្ធរុស្ស៊ី ដល់ក្នុងភូមិព្រៃជីសាក់ ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ , ផ្លូវលំភូមិស្រុកចេក បណ្តោយ១,៤២០ម៉ែត្រ ទទឹង៦ម៉ែត្រ ផ្ទៃក្រឡា ៨,៥២០ម៉ែត្រការ៉េ ចាប់ពីភូមិស្រុកចេក ដល់ភូមិព្រែកថ្លឹង ក្នុងសង្កាត់ជើងឯក ខណ្ឌដង្កោ និង ផ្លូវលំភូមិត្រពាំងរំចេក បណ្តោយ១,១០០ម៉ែត្រ ទទឹង ៨ម៉ែត្រ ផ្ទៃក្រឡា ៨,៨០០ម៉ែត្រការ៉េ ចាប់ពីផ្លូវព្រៃស ដល់វត្តកំពែង ក្នុងខណ្ឌពោធិ៍សែនជ័យ និង ខណ្ឌដង្កោ រាជធានីភ្នំពេញ ជូនរដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៧ ។

រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានីភ្នំពេញ ដែលមានអាសយដ្ឋានលេខ៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ២៥... ខែ កញ្ញា... ឆ្នាំ២០១៧ តទៅ រៀងរាល់ម៉ោងធ្វើការ(ទូរស័ព្ទទាក់ទងលេខ ០១៦ ៧៥៥០០៥)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង០៨:៣០...ថ្ងៃទី...២៦........ខែ.តុលា......ឆ្នាំ២០១៧ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង០៨:៣០ ថ្ងៃទី ២៦...... ខែ តុលា....... ឆ្នាំ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ...១៥... ខែ សីហា.... ឆ្នាំ២០១៧

**អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងជា**
**ប្រធានគណៈកម្មាធិការលទ្ធកម្មរាជធានីភ្នំពេញ**

**ឃួង ស្រេង**

ចម្លងជូន ៖

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ